# ជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រ សង្ខេបគោលការណ៍

Kaiser Permanente មានកម្មវិធីជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រ (MFA) ដើម្បីជួយអ្នកជំងឺបង់ប្រាក់សម្រាប់ការថែទាំ។ វាអាចរ៉ាប់រងលើការចំណាយទាំងអស់ ឬមួយផ្នែករបស់អ្នកសម្រាប់ការថែទាំចាំបាច់រួមទាំងថ្នាំពេទ្យ ដែលផ្តល់ដោយ Kaiser Permanente។ ការទទួលបានជំនួយអាស្រ័យលើតម្រូវការហិរញ្ញវត្ថុដូចបានរៀបរាប់ខាងក្រោម។

## តើអ្នកណាមានសិទ្ធិ?

អ្នកអាចមានសិទ្ធិទទួលបាន ប្រសិនបើអ្នកមានប្រាក់ចំណូលទាប គ្មានការធានារ៉ាប់រង ឬធានារ៉ាប់រងមិនគ្រប់គ្រាន់។ ជាទូទៅ អ្នកមានសិទ្ធិទទួលបានជំនួយផ្នែកហិរញ្ញវត្ថុ៖

- ប្រសិនបើប្រាក់ចំណូលគ្រួសាររបស់អ្នកស្ថិតនៅ ឬទាបជាង 300% នៃគោលការណ៍ណែនាំនៃភាពក្រីក្ររបស់សហព័ន្ធ
- ឬបើអ្នកមានថ្លៃព្យាបាលខ្ពស់ខ្លាំងបើធៀបនឹងចំណូលរបស់អ្នក។

## តើកម្មវិធីនឹងចំណាយលើអ្វី?

កម្មវិធី MFA អាចជួយអ្នកក្នុងការចំណាយលើការថែទាំចាំបាច់ដែលផ្តល់ដោយ Kaiser Permanente។ នេះរួមបញ្ចូលទាំងការថែទាំគ្រាអាសន្ន និងបន្ទាន់ និងសេវាឱសថស្ថាន។ កម្មវិធីអាចរ៉ាប់រងវិក្កយបត្រពេញលេញ ឬមួយផ្នែករបស់វា។

កម្មវិធីនឹងមិនបង់ប្រាក់សម្រាប់៖

- ការដឹកជញ្ជូនវេជ្ជសាស្ត្រ
- បុព្វលាភថែទាំសុខភាព
- ការចំណាយទាក់ទងនឹងការវះកាត់កែសម្ផស្ស ការថែទាំភាពគ្មានកូន ឬការពពោះជំនួស
- ការថែទាំសុខភាពដែលត្រូវបានផ្តល់ជូននៅខាងក្រៅ Kaiser Permanente
- ការថែទាំដែលអ្នកផ្តល់សេវា Kaiser Permanente សម្រេចចិត្តថាមិនចាំបាច់ខាងវេជ្ជសាស្ត្រទ

សម្រាប់បញ្ជីពេញលេញ សូមអានគោលការណ៍ MFA នៅ kp.org/mfa។

## តើខ្ញុំត្រូវដាក់ពាក្យដោយរបៀបណា?

អ្នកអាចដាក់ពាក្យតាមអ៊ីនធឺណិត តាមប្រអប់សំបុត្រប្រៃសណីយ៍ ទូរសារ ឬដោយផ្ទាល់។ វិធីលឿនបំផុតដើម្បីដាក់ពាក្យគឺចូលទៅកាន់ kp.org/mfa ហើយចុះឈ្មោះដើម្បីទទួលបានតំណភ្ជាប់ទៅការដាក់ពាក្យអនឡាញដែលមានសុវត្ថិភាពរបស់យើង។ ការដាក់ពាក្យអនឡាញនឹងសួរសំណួរមួយចំនួនដើម្បីកំណត់សិទ្ធិទទួលបានរបស់អ្នក។

អ្នកក៏អាចទទួលបានពាក្យសុំមិនទាន់បំពេញមួយនៅ kp.org/mfa។

អ្នកអាចដាក់ពាក្យនៅពេលណាមួយក្នុងពេលចូលព្យាបាល ឬដំណើរការចេញវិក្កយបត្រ។ អ្នកមិនចាំបាច់រង់ចាំវិក្កយបត្រសិន មុននឹងសុំជំនួយនោះទេ។

ក្នុងករណីខ្លះ កម្មវិធី MFA អាចជួយបង់ប្រាក់សម្រាប់ការថែទាំរបស់អ្នកដោយមិនចាំបាច់ដាក់ពាក្យ។

ប្រសិនបើអ្នកមានសិទ្ធិទទួលបានជំនួយ យើងនឹងមិនគិតប្រាក់អ្នកលើសពីចំនួនដែលបានចេញវិក្កយបត្រជាទូទៅ (AGB) សម្រាប់ការថែទាំនោះទេ។ សូមមើល kp.org/mfa សម្រាប់ព័ត៌មានបន្ថែមអំពី AGB ។

## តើព័ត៌មានអ្វីខ្លះដែលខ្ញុំត្រូវការដើម្បីដាក់ពាក្យ?

អ្នកនឹងត្រូវបានគេសួររកព័ត៌មានខាងក្រោមនៅពេលអ្នកដាក់ពាក្យ៖

- ទំហំគ្រួសារ និងព័ត៌មានចំណូលសម្រាប់មនុស្សពេញវ័យទាំងអស់ក្នុងគ្រួសារ
- ថ្លៃថែទាំសុខភាព បើដឹង
- ភស្តុតាងនៃប្រាក់ចំណូល

ការផ្តល់ភស្តុតាងនៃប្រាក់ចំណូលជួយយើងកំណត់ថាតើអ្នកមានលក្ខណៈគ្រប់គ្រាន់ដែរឬទេ។



KAISER PERMANENTE®

*(បន្តពីខាងមុខ)*

**តើនៅពេលណាដែលខ្ញុំដឹងថាតើពាក្យសុំរបស់ខ្ញុំត្រូវបានអនុម័តហើយឬនៅ?**
ប្រសិនបើពាក្យសុំរបស់អ្នកពេញលេញ យើងនឹងផ្ញើលិខិតទៅអ្នកជាមួយនឹងការសម្រេចចិត្តរបស់យើងក្នុងរយៈពេល 30 ថ្ងៃនៃថ្ងៃធ្វើការ។ ប្រសិនបើយើងបដិសេធសំណើរបស់អ្នក លិខិតនោះនឹងរួមបញ្ចូលការណែនាំអំពីរបៀបប្តឹងតវ៉ា។

ប្រសិនបើពាក្យសុំរបស់អ្នកមិនពេញលេញ យើងនឹងទាក់ទងទៅអ្នក។ យើងនឹងផ្តល់ឱ្យអ្នកនូវកាលបរិច្ឆេទដែលអ្នកត្រូវផ្តល់ព័ត៌មានដែលខ្វះខាត។ ប្រសិនបើពាក្យសុំរបស់អ្នកនៅតែមិនពេញលេញ អ្នកប្រហែលជាមិនទទួលបានជំនួយផ្នែកហិរញ្ញវត្ថុទេ។

**តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅឯណា?**
អ្នកអាចទទួលបានព័ត៌មានបន្ថែម និងគោលការណ៍ និងពាក្យសុំរបស់ MFA តាមរយៈ: kp.org/mfa។ ព័ត៌មានមានជាភាសាជាច្រើនក្នុងទម្រង់ដែលអាចចូលប្រើតាមកម្មវិធីអានលើអេក្រង់បាន។ អ្នកក៏អាចទូរសព្ទទៅលេខ **1-844-412-0919** (TTY **711**)។

## ជំនួយហិរញ្ញវត្ថុផ្សេងទៀត

**ទទួលបានជំនួយសម្រាប់ការចំណាយលើការថែទាំសុខភាព**
ប្រសិនបើអ្នកមិនមានការធានារ៉ាប់រងសុខភាពទេ Kaiser Permanente អាចជួយបាន។ ដើម្បីស្វែងយល់អំពីជម្រើសរបស់អ្នក សូមទូរសព្ទទៅលេខ **1-800-479-5764** (TTY **711**) ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ម៉ោង 9 ព្រឹក ដល់ 5 ល្ងាច។

**ទទួលបានជំនួយក្នុងការចំណាយសម្រាប់ការរស់នៅ**
ប្រសិនបើអ្នកត្រូវការជំនួយទាក់ទងនឹងរបស់ចាំបាច់ដូចជាអាហារ ផ្ទះសម្បែង ការបង់ថ្លៃអ៊ីនធឺណិត ឬសេវាសាធារណៈផ្សេងៗ និងច្រើនទៀត សូមចូលទៅកាន់ kp.org/socialhealth។ ឬទូរសព្ទទៅមជ្ឈមណ្ឌលជំនួយសហគមន៍តាមលេខ **1-800-443-6328** (TTY **711**) ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ម៉ោង 8 ព្រឹក ដល់ 5 ល្ងាច។

## របៀបទទួលបានច្បាប់ចម្លងនៃគោលការណ៍ MFA ពាក្យសុំ និងព័ត៌មានកម្មវិធី

**អនឡាញ**
kp.org/mfa

**ទូរសព្ទ**
ទូរសព្ទទៅលេខ
**1-844-412-0919** (TTY **711**)

## វិធីដាក់ពាក្យ

**ដាក់ពាក្យតាមអនឡាញ**
kp.org/mfa

**ផ្ញើទូរសារ**
ផ្ញើទូរសារពាក្យដែលបានបំពេញរបស់អ្នកទៅលេខ 1-855-414-1713

**ផ្ញើតាមប្រអប់សំបុត្រប្រៃសណីយ៍**
ផ្ញើពាក្យសុំដែលបានបំពេញរបស់អ្នកទៅ៖
Kaiser Permanente
MFA Program
2101 East Jefferson Street
Rockville, MD 20852

**យកមកដាក់ដោយផ្ទាល់**
ទម្លាក់ពាក្យសុំដែលបានបំពេញរបស់អ្នកមកកាន់សេវាបម្រើសមាជិកនៅមជ្ឈមណ្ឌលវេជ្ជសាស្ត្រ Kaiser Permanente ណាមួយ។

©Kaiser Foundation Hospitals; Kaiser Foundation Health Plan of Mid-Atlantic States



KAISER PERMANENTE®

# NOTICE OF LANGUAGE ASSISTANCE SERVICES

**English:** If you need help in your language, language assistance is available at no cost to you, 24 hours a day, 7 days a week (closed holidays). Call our Member Service Contact Center at 1-800-464-4000 (TTY 711) for help or visit any registration desk for more information at any Kaiser Permanente hospital, Monday through Friday, 8 a.m. to 5 p.m. Aids and services for people with disabilities, like documents in braille, large print, audio, and other accessible electronical formats are also available.

**Chinese：** 如果您需要使用您的语言获得帮助，我们每周 7 天、每天 24 小时免费提供语言帮助（节假日休息）。请致电 1-800-464-4000 (TTY 711) 联络我们的会员服务联络中心以寻求帮助，或前往任何 Kaiser Permanente 医院的登记台了解更多信息，我们的服务时间为周一至周五上午 8 点至下午 5 点。我们还为残疾人提供辅助工具和服务，例如盲文、大字体、音频和其他无障碍电子格式的文档。

**Spanish:** Si necesita ayuda en su idioma, contamos con asistencia de idiomas sin costo alguno para usted las 24 horas del día, los 7 días de la semana (excepto los días festivos). Comuníquese con nuestra Central de Llamadas de Servicio a los Miembros al 1-800-464-4000 (TTY 711) para obtener ayuda. O visite el mostrador de recepción en cualquier hospital de Kaiser Permanente para obtener más información, de lunes a viernes, de 8 a. m. a 5 p. m. También ofrecemos ayudas y servicios para personas con discapacidades, como documentos en braille, letra grande, audio y otros formatos electrónicos accesibles.